*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# ការរាយការណ៍អំពីការប្រព្រឹត្តរំលោភបំពានលើមនុស្សចាស់ និងមនុស្សពេញវ័យជាជនពិការ

***ខែធ្នូ ឆ្នាំ 2010 ការបោះពុម្ពផ្សាយលេខ 7024.06-Cambodian***

អ្នកទទួលបានការការពារពិសេស បើអ្នកជាមនុស្សពេញវ័យដែលមានពិការភាព ឬជាមនុស្សចាស់ដែលរងការរំលោភបំពាន ត្រូវគេទុកចោលមិនមានអ្នកមើលថែ ឬជាជនគោលដៅចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ ដោយសារតែពិការភាពរបស់អ្នក ។

1. តើអ្វីជាការរំលោភបំពាន? សូមចុចលើតំណមួយនេះ ដើម្បីស្វែងរកមើលថាតើអ្វីជាការរំលោភបំពាន
2. តើអ្វីជាការទុកចោលមិនមានអ្នកមើលថែ? សូមចុចលើតំណមួយនេះ ដើម្បីស្វែងរកមើលថាតើអ្វីជាការទុកចោលមិនមានអ្នកមើលថែ
3. តើអ្វីជាបទឧក្រិដ្ឋ? សូមចុចលើតំណមួយនេះ ដើម្បីស្វែងរកមើលថាតើអ្វីជាបទឧក្រិដ្ឋ

## តើខ្ញុំត្រូវហៅទូរស័ព្ទទៅរកអ្នកណា?

**បើអ្នករស់នៅក្នុងសហគមន៍ ដូចជារស់នៅក្នុងផ្ទះរបស់ខ្លួន សណ្ឋាគារ ឬកំពុងទទួលការថែទាំនៅមន្ទីរពេទ្យ គ្លីនិក ឬកម្មវិធីបណ្តុះបណ្តាល អ្នកគួរទាក់ទងមកកាន់ ៖**

- នាយកដ្ឋាន **នគរបាលមូលដ្ឋាន** ឬនាយកដ្ឋានតម្រួតតំបន់របស់អ្នក ឬហៅទូរស័ព្ទមកលេខ 911 ។

**និង**

- ភ្នាក់ងារ**សេវាកម្មការពារមនុស្សពេញវ័យប្រចាំខោនធី (APS, County Adult Protective Services)** របស់អ្នក ។

ដើម្បីស្វែងរកភ្នាក់ងារសេវាកម្មការពារមនុស្សពេញវ័យប្រចាំខោនធី របស់អ្នក សូមចុច ទីនេះ ។

**បើអ្នករស់នៅក្នុងមណ្ឌលថែទាំ ដូចជាផ្ទះសម្រាប់រស់នៅជាក្រុម ផ្ទះផ្តល់ការថែទាំ ឬមណ្ឌលថែទាំដូចជផ្ទះសម្រាប់ស្នាក់នៅ (ដូចជាកន្លែងមានផ្តល់ជំនួយក្នុងការរស់នៅ ផ្ទះសម្រាប់រស់នៅដែលមានផ្តល់ម្ហូបអាហារ ឬផ្ទះសម្រាប់ផ្តល់ការថែទាំ) អ្នកគួរទាក់ទង ៖**

- នាយកដ្ឋាន **នគរបាលមូលដ្ឋាន** ឬនាយកដ្ឋានតម្រួតតំបន់របស់អ្នក ឬហៅទូរស័ព្ទមកលេខ 911 ។

**និង**

- **មន្ត្រីស៊ើបអង្កេតការផ្តល់ការថែទាំរយៈពេលវែង (LTCO, Long-Term Care Ombudsman)** ។ ដើម្បីស្វែងរកមើលកម្មវិធីស្នាក្តីសាធារណៈប្រចាំមូលដ្ឋានរបស់អ្នក សូមចុចទីនេះ ឬហៅទូរស័ព្ទមកកាន់ LTCO របស់រដ្ឋ ផ្នែកដោះស្រាយវិបត្ត តាមលេខ 1-800-231-4024 ។

**និង**

- **ក្រសួងសុខាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា (DPH, California Department of Public Health)** ។ ក្រសួងសុខាភិបាលរដ្ឋកាលីហ្វ័រនីញ៉ា គឺជាអ្នកមើលការខុសត្រូវមណ្ឌលសុខភាព និងជាអ្នកស៊ើបអង្កេតបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ និងការផ្តល់ការថែទាំមិនជិតដល់ ។ លេខទូរស័ព្ទនៃការិយាល័យប្រចាំមូលដ្ឋានរបស់អ្នក អាចរកបានដោយចុចទីនេះ ។

**និង**

- **ការិយាល័យអគ្គមេធាវីរដ្ឋកាលីហ្វ័រនីញ៉ាផ្នែកការក្លែងបន្លំ Medi-Cal និងការរំលោភបំពានមនុស្សចាស់ (BMFEA, California Attorney General Bureau of Medi-Cal Fraud and Elder Abuse)** ដែលមានតួនាទីការពារអ្នកពីការរំលោភបំពាន ឬការទុកចោលមិនមើលថែនៅផ្ទះផ្តល់ការថែទាំ និងនៅមណ្ឌលផ្តល់ការថែទាំយូរអង្វែងផ្សេងៗទៀត។ ដើម្បីរាយការណ៍អំពីការរំលោភបំពានចំពោះអ្នក សូមទាក់ទងមកកាន់ការិយាល័យអគ្គមេធាវី តាមទូរស័ព្ទទាន់ហេតុការណ៍ដែលហៅដោយមិនអស់ប្រាក់ គឺលេខ (800) 722-0432 ឬទាក់ទងតាមទំព័រវិប ដោយការចុចទីនេះ ។

## ច្បាប់ និងបទបញ្ញត្តិ

- ក្រមរដ្ឋប្បវេណីកាលីហ្វ័រនីញ៉ា (Welf. & Inst. Code) §§ 15630-15632 ច្បាប់ការពាររដ្ឋប្បវេណីចំពោះការរំលោភបំពានលើមនុស្សចាស់ និងមនុស្សពេញវ័យដែលពិការ (Elder Abuse and Dependent Adult Abuse Civil Protection Act)
- ក្រមរដ្ឋប្បវេណីកាលីហ្វ័រនីញ៉ា (Welf. & Inst. Code) § 15700 ការបញ្ជូនមនុស្សពេញវ័យដែលងាយរងគ្រោះឲ្យទទួលបានការការពារ និងការថែទាំ (Protective Placements and Custody of Endangered Adults)
- ក្រមរដ្ឋប្បវេណីកាលីហ្វ័រនីញ៉ា (Welf. & Inst.) §§ 15703-15705.40 សេវាកម្មការពារ
- ក្រមព្រហ្មទណ្ឌកាលីហ្វ័រនីញ៉ា (Cal. Pen. Code) § 368 ឧក្រិដ្ឋកម្មប្រឆាំងមនុស្សចាស់ និងមនុស្សពេញវ័យដែលពិការ (Crimes Against Elders and Dependent Adults)

## តើអង្គការ Disability Rights California ជាអ្វី?

អង្គការ Disability Rights California គឺជាអង្គការមិនរកកម្រៃ ដែលធ្វើការគាំពារ និងជួយអ្នកដោះស្រាយបញ្ហាពាក់ព័ន្ធនឹងពិការភាពរបស់អ្នក ។ សេវាកម្មរបស់អង្គការយើងខ្ញុំ មានដូចជា ៖

1. ប្រាប់អ្នកឲ្យដឹងអំពីសិទ្ធិផ្លូវច្បាប់ សិទ្ធិពលរដ្ឋ និងសិទ្ធិទទួលបានសេវាកម្មរបស់អ្នក
2. ស៊ើបអង្កេតបណ្តឹងអំពីការប្រព្រឹត្តរំលោភរាងកាយ ផ្លូវភេទ ឬការទុកចោលមិនមើលថែទាំ
3. ធ្វើជាតំណាងជនពិការ ផ្នែកការអប់រំ ការរើសអើង អត្ថប្រយោជន៍ និងការងារ ។

បើអ្នកមានបញ្ហាអ្វីមួយពាក់ព័ន្ធនឹងពិការភាពរបស់អ្នក អ្នកអាចទាក់ទងមកកាន់ការិយាល័យណាមួយរបស់យើងខ្ញុំ តាមលេខ **1-800-776-5746** ឬតាមអ៊ិនធឺណិត ដោយការចុចទីនេះ ។

## និយមន័យ ៖

### ការរំលោភបំពាន គឺ ៖

ការរំលោភបំពាន អាចសំដៅលើរឿង 3 ផ្សេងគ្នា ៖

1. **រំលោភបំពានរាងកាយ ៖**
   នរណាម្នាក់ធ្វើឲ្យអ្នកឈឺចាប់ផ្នែករាងកាយ ដោយមានចេតនា
   - ឧទាហរណ៍ ៖ កាយវាយ ទាត់ធាក់ ដុត ខាំ អង្រួន ឬប្រើរបស់វាយលើរាងកាយអ្នក ។
   - ចំពោះស្ថានភាពនេះ គឺមិនចាំបាច់ទាល់តែមានការហើមជាំ ឬឈឺលើរាងកាយអ្នកឡើយ ទើបហៅថាអ្នកបានរងការរំលោភបំពានលើរាងកាយ ។
2. **រំលោភបំពានផ្លូវភេទ ៖**
   នរណាម្នាក់ប៉ះរាងកាយអ្នក ដោយមានបំណង ដែលធ្វើឲ្យអ្នកមិនសុខស្រួលក្នុងចិត្ត
   - ការប៉ះពាល់បរិវេណលាក់កំបាំងរបស់អ្នក
   - ប៉ះពាល់អ្នកពេលអ្នកពាក់ខោអាវងូតទឹក
   - ថតរូបអ្នកពេលអ្នកស្រាត
   - ប៉ះពាល់បរិវេណលាក់កំបាំងរបស់ពួកគេនៅពីមុខអ្នក
3. **ការរំលោភបំពានផ្នែកអារម្មណ៍ ៖**
   នរណាម្នាក់ប្រើភាសា ឬមធ្យោបាយមិនពាក់ព័ន្ធនឹងរាងកាយ ដើម្បីធ្វើឲ្យអ្នកឈឺចាប់ ដោយចេតនា
   - ប្រើពាក្យសំដីគម្រាមអ្នក
   - ធ្វើឲ្យអ្នកខ្មាសគេដោយមានចេតនា
   - ជេរអ្នក
   - និយាយមើលងាយអ្នក
   - មិនឲ្យអ្នកជួបមនុស្សដែលអ្នកចង់ជួប
   - មិនឲ្យអ្នកធ្វើអ្វីដែលអ្នកពេញចិត្ត
   - បញ្ចេញកាយវិការគម្រាមកំហែងចំពោះអ្នក

### ការមិនយកចិត្តទុកដាក់មើលថែ គឺ ៖

នៅពេលដែលនរណាម្នាក់ដែលមានតួនាទីមើលថែទាំអ្នក មិនធ្វើការថែទាំអ្នកតាមអ្វីដែលអ្នកត្រូវការ ដូចជា ៖

1. មិនឲ្យចំណីអាហារ សម្លៀកបំពាក់ គ្រប់គ្រាន់ ឬមិនផ្តល់ជម្រកស្នាក់អាស្រ័យដល់អ្នក
2. មិនផ្តល់ឲ្យអ្នកនូវតម្រូវការផ្នែករាងកាយ និងវេជ្ជសាស្ត្រ
3. មិនសំអាតខ្លួនប្រាណឲ្យអ្នក

4. មិនឲ្យអ្នកលេបថ្នាំ
5. មិនជួយអ្នកក្នុងការធ្វើចលនាជុំវិញកន្លែងរស់នៅ
6. មិនសំអាតបរិវេណរស់នៅ ដើម្បីអ្នកអាចដើរដោយមិនដួល

**បទឧក្រិដ្ឋ គឺជា ៖**

បើនរណាម្នាក់ រំលោភបំពានអ្នក ឬ មិនយកចិត្តទុកដាក់មើលថែទាំអ្នក
គឺគេ**ហៅថាជាបទឧក្រិដ្ឋហើយ!!!**

បទឧក្រិដ្ឋ ក៏មានរួមបញ្ចូលចំណុចមួយចំនួនទៀត ដូចជា ៖

1. ការធ្វើទុក្ខរាងកាយដោយខុសទំនង ៖
   - ឧទាហរណ៍ ៖ ចងអ្នកជាប់មិនឲ្យទៅណាមកណាបាន
   - ប្រើអ្វីមួយដើម្បីរារាំងអ្នកមិនឲ្យធ្វើចលនាបាន
   - ចាប់ ឬក្រៀកអ្នកកុំឲ្យធ្វើចលនាបាន

2. ការប្រើសារធាតុគីមី ឬថ្នាំពេទ្យដែលមិនត្រឹមត្រូវ ៖
   - ឧទាហរណ៍ ៖ ឲ្យអ្នកលេបថ្នាំដែលធ្វើឲ្យអ្នកងងុយគេង ឬអស់កំលាំងល្ហិតល្ហៃ តែវាមិនបានធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្រាលក្នុងខ្លួនឡើយ

3. ការរំលោភផ្នែកហិរញ្ញវត្ថុ ៖
   - ឧទាហរណ៍ ៖ នៅពេលនរណាម្នាក់យកប្រាក់ ឬទ្រព្យសម្បត្តិរបស់អ្នក ដោយមិនមានការអនុញ្ញាតពីអ្នក
   - ទោះជាអ្នកនោះជាសមាជិកក្នុងគ្រួសារអ្នកក៏ដោយ ក៏ត្រូវចាត់ទុកជាការរំលោភហិរញ្ញវត្ថុដែរ បើពួកគេយកប្រាក់ ឬរបស់ទ្រព្យរបស់អ្នកដោយគ្មានការអនុញ្ញាតពីអ្នក ។

---

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ ហើយប្រាប់ឲ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ! [ចាប់ផ្តើមបំពេញសំណួរសម្រង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។ សម្រាប់គោលបំណងផ្សេងៗទៀតទាំងអស់

សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html